សម្រង់អត្ថបទជំនួយស្មារតី

(នីតិរដ្ឋបាលទូទៅ)

ស្តីពី

# រដ្ឋបាល



បង្រៀនដោយ៖


សាស្ត្រាចារ្យបណ្ឌិត ថេង ច័ន្ទសង្វារ

រៀបចំដោយ៖ ដួន ឋិតបេរឫទ្ធិ (សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៧)



នាំមកជូនដោយ៖ នីតិកោសល

ខែកក្កដា ឆ្នាំ២០២០

# ១. និយមន័យ



រដ្ឋបាលគឺជាអង្គការចាត់តាំងសាធារណៈក្រោមការដឹកនាំរបស់រដ្ឋបាលភិបាលក្នុងសកម្មភាពសាធារណៈ ដែលរួមមានការកំណត់វិធាន ការរកយុត្តិធម៌ ការដឹកនាំ និងការគ្រប់គ្រង ដើម្បីសម្រេចនូវគោលដៅនៃការបម្រើប្រយោជន៍សាធារណៈ ដោយប្រើមធ្យោបាយពិសេសរបស់រដ្ឋបាល គឺបុព្វសិទ្ធនៃអំណាចសាធារណៈ និងការបង្ខំធម្មានុរូប។

រដ្ឋបាល ជាសញ្ញាណមួយដែលមានន័យជា "អង្គភាព" ផងនិង "សកម្មភាព" ផង។ លក្ខណៈពិសេសនៃរដ្ឋបាលគឺវិធានគតិយុត្ត ពីព្រោះរដ្ឋបាលធ្វើសកម្មភាពសាធារណៈ ដែលផ្ទុយពីរដ្ឋបាលក្នុងវិស័យឯកជនដែលប្រើសម្រាប់តែការងារបុគ្គលិក ផ្គត់ផ្គង់ និងហិរញ្ញវត្ថុនៅក្នុងក្រុមហ៊ុន ឬទំនាក់ទំនងការងាររបសខ្លួនប៉ុណ្ណោះ។

## ២. សកម្មភាពសាធារណៈ

- កំណត់វិធាន (legislate) ៖ រដ្ឋបាលអាចកំណត់វិធានគតិយុត្តទាំងឡាយណាដែលស្របទៅនឹងច្បាប់ (ឬដែលសភាប្រគល់អំណាចឲ្យ) ដើម្បីអនុវត្ត ឬធ្វើចំណាត់ការការងាររដ្ឋបាល។ វិធានទាំងនោះ មានដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា។ វិធានទាំងនេះ គឺចេញដោយរដ្ឋបាល ចំណែកឯច្បាប់(ឬក្រម) ត្រូវចេញដោយស្ថាប័ននីតិបញ្ញត្តិ (រដ្ឋសភា និងព្រឹទ្ធសភា) ដូចជាច្បាប់ភូមិបាល ច្បាប់អប់រំ ច្បាប់អស្សាមិករណ៍...



ចំណែកឯយុត្តិសាស្ត្រវិញ គឺចេញដោយចៅក្រម។ នេះបង្ហាញឲ្យឃើញពីភាពដាច់ចេញពីគ្នាដោយឯករាជ្យរវាងអំណាចនីតិបញ្ញត្តិ (ដឹកនាំដោយស្ថាប័នរដ្ឋសភា និងព្រឹទ្ធសភា)

អំណាចនីតិប្រតិបត្តិ (ដឹកនាំដោយរដ្ឋាភិបាលដែលមានរដ្ឋបាលជាបេះដូង) និងអំណាចតុលាការ (ជម្រះក្ដីដោយចៅក្រម ឬក្រុមប្រឹក្សាជំនុំជម្រះ)។ វិធានរបស់រដ្ឋបាល មានអំណាចអនុវត្តដោយចាប់បង្ខំ (ជាកាតព្វកិច្ច) ទោះមិនទាន់ដឹងថាវិធាននោះខុស ឬត្រូវនៅឡើយក៏ដោយ គឺចាំបាច់ត្រូវតែគោរព និងអនុវត្តតាមជាមុនសិន ប៉ុន្តែគេអាចប្ដឹងទៅតុលាការដើម្បីពន្យាការអនុវត្តវិធាននោះ ដើម្បីបង្ការនូវព្យសនកម្មផ្សេងៗ ដែលអាចកើតឡើងពីការអនុវត្តវិធាននោះ ហើយរង់ចាំលទ្ធផលនៃការ ពិនិត្យឡើងវិញពីភាពស្របច្បាប់នៃវិធាននោះ (ការពិនិត្យមើលនីត្យានុកូលភាពនៃវិធានដែលចេញដោយរដ្ឋបាល)។ ឧទាហរណ៍ ប្រសិនបើអាជ្ញាធរខេត្តចេញសេចក្ដីសម្រេចឲ្យវាយកំទេចផ្ទះមួយដោយមូលហេតុថាជាសំណង់ខុសច្បាប់ ឬខុសបច្ចេកទេស តើម្ចាស់អចលនៈទ្រព្យ (ម្ចាស់ផ្ទះ) ត្រូវអនុវត្តសេចក្ដីសម្រេចនេះដែរ ឬទេ? បើមិនអនុវត្ត គឺមិនគោរពវិធានរដ្ឋបាល (មិនគោរពច្បាប់) តែបើអនុវត្តតាមសេចក្ដីសម្រេចនេះ ម្ចាស់ផ្ទះនឹងខាតបង់ទ្រព្យសម្បត្តិរបស់ខ្លួន។ ចម្លើយ គឺត្រូវតែអនុវត្តតាម ប៉ុន្តែម្ចាស់ផ្ទះត្រូវប្ដឹងទៅតុលាការជាបន្ទាន់ ដើម្បីស្នើសុំឲ្យមានការពន្យាការអនុវត្តសេចក្ដីសម្រេចនេះ ដើម្បីទុកពេលឲ្យតុលាការសិក្សាទៅលើសេចក្ដីសម្រេចនេះថាតើខុស ឬត្រឹមត្រូវតាមច្បាប់។

- រកយុត្តិធម៌ (do justice)៖ ការរកយុត្តិធម៌នៅទីនេះ សំដៅទៅលើ (១) **ការសម្របសម្រួល** ឬដោះស្រាយទំនាស់តាមមធ្យោបាយក្រៅប្រព័ន្ធតុលាការ (ដូចជា អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្ដាល គណៈកម្មការដោះស្រាយវិវាទដីធ្លី) (២) **ការធានាសមធម៌សង្គម** ដោយរដ្ឋាភិបាលចាំបាច់ត្រូវធានាឲ្យមានការអភិវឌ្ឍនៅតាមតំបន់ដាច់ស្រយាល តំបន់ព្រំដែន តំបន់ងាយរងគ្រោះ ឲ្យមានការរីកចម្រើនប្រហាក់ប្រហែលទៅនឹងតំបន់ទីប្រជុំជន ឬទីក្រុងដែរ ក្នុងគោលដៅកាត់បន្ថយគម្លាតរវាងទីក្រុង និងទីជនបទ និង (៣) **រក្សាលំនឹងសង្គម**។ ឧទាហរណ៍ ការសម្របសម្រួលបញ្ហាឈ្លោះប្រកែកគ្នារបស់ប្រជាពលរដ្ឋ ការលះលែងគ្នា បញ្ហាគោស៊ីស្រូវ អំពើហិង្សាក្នុងគ្រួសារ គឺសុទ្ធតែមាន



ការចូលរួមដោះស្រាយដោយមេឃុំ មេភូមិ ឬប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ។ល។និង។ល។ ទាំងអស់នេះគឺជាសកម្មភាពរកយុត្តធម៌របស់រដ្ឋបាល ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នបានអនុវត្តនយោបាយផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋ ដើម្បីកសាងលំដ្ឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ គឺជាកិច្ចការរកយុត្តិធម៌ឲ្យប្រជាពលរដ្ឋដ៏សំខាន់មួយរបស់រដ្ឋាភិបាល។ ការរកយុត្តិធម៌ជាសកម្មភាពសាធារណៈមួយរបស់រដ្ឋបាល ខុសពីការរកយុត្តិធម៌ដោយតុលាការដែលផ្តោតទៅលើការជម្រះក្តីដោយចៅក្រម។

- ដឹកនាំ (govern) ៖ សំដៅទៅលើការសម្រេចចិត្តកម្រិតនយោបាយដើម្បីតម្រង់ទិស និងកំណត់គោលដៅឲ្យថ្នាក់ក្រោមអនុវត្តតាម។ រដ្ឋបាលដែលដឹកនាំការងារសម្រេចចិត្តក្នុងកម្រិតនយោបាយ គឺជាសមាជិករាជរដ្ឋាភិបាល ដែលរួមមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។



- គ្រប់គ្រង (manage) ៖ ជាការងារក្នុងកម្រិតបច្ចេកទេសដោយត្រូវអនុវត្តប្រចាំថ្ងៃដើម្បីសម្រេចគោលដៅដែលបានកំណត់ខាងលើ។ រដ្ឋបាលដែលគ្រប់គ្រងការងារក្នុងកម្រិតបច្ចេកទេស គឺសំដៅទៅលើកម្រិតដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃមុខងារសាធារណៈ ចាប់ពីអគ្គនាយក ឬអភិបាលខេត្តចុះក្រោម។



## ៣. គោលដៅរបស់រដ្ឋបាល

- ប្រយោជន៍សាធារណៈ ៖ ដើម្បីសម្គាល់ថាសកម្មភាពមួយបម្រើប្រយោជន៍សាធារណៈ ឬអត់ ចាំបាច់ត្រូវពិនិត្យលើពេលវេលា និងទីកន្លែង។

# ៤. មធ្យោបាយរបស់រដ្ឋបាល



ដើម្បីធ្វើសកម្មភាពទាំង៤ខាងលើ និងសម្រេចបាននូវគោលដៅនៃការបម្រើប្រយោជន៍សាធារណៈ រដ្ឋបាលប្រើមធ្យោបាយគតិយុត្តមួយហៅថា "បុព្វសិទ្ធិនៃអំណាចសាធារណៈ និងការបង្ខំធម្មានុរូប" ដែលក្នុងនោះមានរាប់បញ្ចូលនូវមធ្យោបាយចំនួន ៣ គឺ៖ (១) **វិសមភាពគតិយុត្ត** (២) **សេចក្តីសម្រេចឯកតោភាគី** និង (៣) **អស្សាមិករណ៍ និងកំណែន**។ កាលណាគេនិយាយពីមធ្យោបាយគតិយុត្ត គឺគេប្រើសម្រាប់ការសិក្សាក្នុងមុខវិជ្ជានីតិរដ្ឋបាល តែបើគេនិយាយពីមធ្យោបាយរូបវន្ត (មនុស្ស និងហិរញ្ញវត្ថុ) គឺគេសិក្សាក្នុងវិទ្យាសាស្ត្ររដ្ឋបាល។

- បុព្វសិទ្ធនៃអំណាចសាធារណៈ និងការបង្ខំធម្មានុរូប ៖ បុព្វសិទ្ធនៃអំណាចសាធារណៈ ជាសិទ្ធិចម្បង ឬសិទ្ធិពិសេសដែលរដ្ឋបាលមានតែឯកជនគ្មាន រីឯការបង្ខំធម្មានុរូប គឺជាការបង្ខំដែលស្របច្បាប់ ឬដែលអនុគ្រោះដោយច្បាប់ដូចជា ការដាក់ស្តុបបង្ខំឲ្យអ្នកដំណើរគោរពភ្លើងសញ្ញាចរាចរណ៍ ការបង្ខំឲ្យអ្នកជិះម៉ូតូពាក់មួកសុវត្ថិភាព។ល។ ការបង្ខំនេះ អាចធ្វើឲ្យអ្នកដំណើរធុញថប់នឹងការបញ្ឈប់ដោយភ្លើងសញ្ញាចរាចរណ៍ អ្នកជិះម៉ូតូមិនសប្បាយចិត្តនៅពេលដែលពាក់មួកសុវត្ថិភាពវាអាចធ្វើឲ្យខូចម៉ូតសក់ មិនអាចមើលឃើញទេសភាពច្បាស់ ឬធ្វើឲ្យហាប់ខ្យល់ជាដើម ជាពិសេសទៅទៀត វាជាសុវត្ថិភាពផ្ទាល់ខ្លួនគេ ហេតុអ្វីបង្ខំគេ ហេតុអ្វីកាត់បន្ថយការធ្វើដំណើរដោយសេរីរបស់គេ។ ប៉ុន្តែ ប្រសិនបើអ្នកដំណើរមិនគោរពតាមការបង្ខំ (ច្បាប់) ពួកគេអាចជួបប្រទះនឹងគ្រោះថ្នាក់ចរាចរណ៍បណ្តាលឲ្យរបួស ពិការ បាត់សតិ ឬរហូតដល់បាត់បង់ជីវិត ដែលជាបច្ច័យធ្វើឲ្យមានកូនកំព្រា គ្មានអ្នកចិញ្ចឹម កូនមិនបានទៅរៀន គ្រួសារបាត់បង់ចំណូល ដែលជាបន្ទុកដ៏ធ្ងន់ធ្ងររបស់ក្រុមគ្រួសារ និងសង្គមជាតិ។ ដូចនេះ ការបង្ខំឲ្យគោរពភ្លើងសញ្ញាចរាចរណ៍ ការបង្ខំឲ្យពាក់មួកសុវត្ថិភាព គឺជាឧទាហរណ៍មួយដែលបង្ហាញពីការបង្ខំដែលមានធម្មានុរូប ពីព្រោះវាមានគោលដៅការពារព្យសនកម្ម រក្សាសណ្តាប់ធ្នាប់



និងបម្រើប្រយោជន៍សាធារណៈ។

ចំពោះការការពារធម្មានុរូប អាចធ្វើឡើងក្នុងលក្ខខណ្ឌបីយ៉ាងគឺ (១) ការបង្ខំដោយជាក់ស្តែង ឬស្ថានភាពជាក់ស្តែង (២) គ្មានមធ្យោបាយផ្សេង ឬគេចមិនរួច និង (៣) ការការពារត្រូវតែសមាមាត្រទៅនឹងគ្រោះថ្នាក់ដែលអាចកើតឡើង។ ឧទាហរណ៍ ចោរលួចចូលផ្ទះដោយគ្មានកាន់អាវុធអ្វីទាំងអស់ តែពេលម្ចាស់ឃើញស្រាប់តែយកកាំភ្លើងបាញ់ចោរនោះឲ្យរបួស ឬស្លាប់តែម្តង។ នេះគេមិនចាត់ទុកជាការការពារដោយធម្មានុរូបទេ ពីព្រោះការការពារនេះប្រើកំភ្លើងឆ្លើយតបក្នុងខណៈពេលដែលចោរពុំមានអាវុធអ្វីសោះនៅក្នុងដៃ គឺមិនសមាមាត្រទៅនឹងគ្រោះដែលអាចនឹងកើតឡើង។

- វិសមភាពគតិយុត្ត ៖ សំដៅទៅលើភាពមិនស្មើគ្នាតាមផ្លូវច្បាប់រវាងរដ្ឋបាល និង




ឯកជន។ ឧទាហរណ៍ រដ្ឋបាលមានសិទ្ធិលុបកិច្ចសន្យាស្តីពីការសម្បទានដីសេដ្ឋកិច្ច ឬព្រៃសម្បទានរវាងរដ្ឋ និងក្រុមហ៊ុនឯកជនបាន ដោយឯកជនមិនអាចបដិសេធបានទោះជាមិនទាន់ផុតរយៈពេលនៃសម្បទានក្តី។ ទន្ទឹមនឹងនេះ រដ្ឋបាលក៏មាននីតិវិធីផ្តល់យុត្តធម៌ដល់ភាគីឯកជនវិញស្របទៅតាមលក្ខខណ្ឌច្បាប់ និងកិច្ចសន្យា។ ឧទាហរណ៍ផ្សេងទៀត សមត្ថកិច្ចមានសិទ្ធិចាប់ពលរដ្ឋដែលប្រព្រឹត្តខុស ប៉ុន្តែពលរដ្ឋវិញមិនអាចចាប់សមត្ថកិច្ចវិញបានទេ។

- សេចក្តីសម្រេចឯកតោភាគី ៖ ជាការសម្រេចចិត្តដោយរដ្ឋបាល ឬបុគ្គលអាជ្ញាធររដ្ឋបាល



ក្នុងភាគីម្នាក់ឯង តែមានឥទ្ធិពលទៅលើតតិយជន (មន្ត្រីរដ្ឋបាលតាមឋានានុក្រមត្រូវគោរព និងអនុវត្ត ហើយប្រជាជនត្រូវគោរពតាមសេចក្តីសម្រេចឯកតោភាគីនេះ។) ឧទាហរណ៍ ព្រះរាជក្រឹត្យស្តីពីក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល អនុក្រឹត្យលេខ១០៣ អនក្រ.បក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន គឺសុទ្ធតែជាសេចក្តីសម្រេចឯកតោភាគី។

- អស្សាមិករណ៍ និងកំណែន ៖ អស្សាមិករណ៍សំដៅទៅលើការយកទ្រព្យសម្បត្តិ ឬ



អចលនទ្រព្យរបស់ឯកជន/ប្រជាជន ដើម្បីធ្វើជាប្រយោជន៍សាធារណៈ។ ឧទាហរណ៍ ការកសាងស្ពានទន្លេបិទ ការពង្រីកផ្លូវជាតិលេខ៦ មានការប៉ះពាល់ដល់ដី និងផ្ទះរបស់ប្រជាពលរដ្ឋ ប៉ុន្តែរដ្ឋបាលមានអំណាចតាមផ្លូវច្បាប់ក្នុងការរឹបអូសយកដី ឬវាយរបងផ្ទះរបស់ប្រជាជន ដោយអនុវត្តតាមនីតិវិធីច្បាប់ និងផ្តល់សំណងសមរម្យជាមុន ដើម្បីកសាងស្ពាន/ផ្លូវ ក្នុងគោលបំណងបម្រើដល់ប្រយោជន៍សាធារណៈ។

ចំណែកឯកំណែនមានន័យថា រដ្ឋបាលមានអំណាចកែនកម្លាំងប្រជាពលរដ្ឋ (បុរសដែលគ្រប់អាយុ) ដើម្បីធ្វើទាហានក្នុងករណីប្រទេសជាតិជួបភាពអាសន្នដោយសារការឈ្លានពានរបស់បរទេស។ មួយវិញទៀត រដ្ឋបាលមានអំណាចក្នុងការកែនកម្លាំងពលកម្មដើម្បីបម្រើការងារសហគមន៍នៅក្នុងសហគមន៍ ដូចជា ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការកសាងផ្លូវលំ ការជីកស្រះ ការលើកទំនប់របស់សហគមន៍ ។ល។

បុព្វសិទ្ធិនៃអំណាចសាធារណៈ និងការបង្ខំធម្មានុរូបខាងលើនេះ គឺសុទ្ធតែធ្វើឡើងក្នុងគោលដៅបម្រើប្រយោជន៍សាធារណៈទាំងអស់ តែក៏មិនធ្វើឲ្យប៉ះពាល់ខ្លាំងពេកចំពោះសិទ្ធិប្រជាពលរដ្ឋដែរ។

*សូមអរគុណ*